Cambodian Women's Crisis Center

# របាយការណ៍ប្រចាំឆ្នាំ ២០២២

## *ជួយស្ត្រីដើម្បីអោយស្ត្រីជួយខ្លួនឯង*



*ស្ត្រីនិងកូនតូចរបស់គាត់ស្នាក់នៅមណ្ឌលសុវត្ថិភាព*

## សេចក្តីផ្តើម

បើទោះជាមានយន្តការជាតិនិងយន្តការទាំងឡាយ ត្រូវបានដាក់ឲ្យអនុវត្តន៍ ដើម្បីលើកកម្ពស់សមភាពយេនឌ័រនៅកម្ពុជាយ៉ាងណាក៏ដោយ យើងមិនអាចនិយាយបានថា សមភាពយេនឌ័រនៅកម្ពុជាសម្រេចបានទាំងស្រុងនោះទេ។ ស្ត្រីភាគច្រើនដែលរស់នៅទីជនបទដាច់ស្រយាលពុំទទួលបាននូវសិទ្ធិជាមូលដ្ឋានរបស់ខ្លួននោះទេ ដោយស្ត្រីនិងក្មេងស្រីទាំងនោះមិនទទួលបាននូវភាពស្មើគ្នាក្នុងការទទួល សេវាថែទាំសុខភាព ការអប់រំ អាជីពការងារ និងការចូលរួមផ្នែកនយោបាយ។ មួយវិញទៀត អំពើហិង្សាក៏បាននិងកំពុងកើតមានឡើងជារៀងរាល់ថ្ងៃ ដែលបង្ករឲ្យមានអស្ថេរភាពក្នុងគ្រួសារ ភាពក្រីក្រ និងការធ្លាក់ចុះនូវធនធានមនុស្ស។ កត្តាទាំងនេះ បានជះឥទ្ធិពលអាក្រក់មកលើប្រជាជនជាច្រើនជាពិសេសគឺស្ត្រី ដែលធ្វើឲ្យពួកគេពុំអាចប្រើប្រាស់សិទ្ធិមនុស្សជាសកលរបស់ខ្លួនបាន។

អង្គការ CWCC បាននឹងកំពុងធ្វើការយ៉ាងជិតស្និត ជាមួយម្ចាស់ជំនួយដោយទទួលបានការគាំទ្រ និង ការគិតគូរអំពីបំលាស់ប្តូរនិន្នាការនៅក្នុងការផ្តល់មូលនិធិរបស់ម្ចាស់ជំនួយ ។

អង្គការ CWCC ផ្តោតការយកចិត្តទុកដាក់ក្នុងការធ្វើអន្តរាគមន៍ និងផ្តល់សេវាដើម្បីកាត់បន្ថយអំពើហិង្សា និងពង្រឹងសិទ្ធអំណាចដល់ស្ត្រី ជាពិសេសពាក់ព័ន្ធនឹងបញ្ហាអំពើរហិង្សាក្នុងគ្រួសារ ការរំលោភសេពសន្ថវៈ ការរំលោភបំពានផ្លូវភេទ និងការជួញដូរផ្លូវភេទ ការជួញដូរស្ត្រី និងកុមារ និងការទទួលបានភាពស្មើរគ្នារបស់ក្មេងស្ត្រីក្នុងវិស័យអប់រំ ។

## វិធីសាសស្ត្ររបស់អង្គការ




## តំបន់គោលដៅរបស់អង្គការ

- រាជធានីភ្នំពេញ៖ ការិយាល័យប្រចាំតំបន់ និង មណ្ឌលសុវត្ថិភាព
- ខេត្តសៀមរាប៖ ការិយាល័យប្រចាំតំបន់ និង មណ្ឌលសុវត្ថិភាព

- ខេត្តបន្ទាយមានជ័យ៖ ការិយាល័យប្រចាំតំបន់ និង មណ្ឌលសុវត្ថិភាព
- ខេត្តកំពង់ធំ៖ ការិយាល័យប្រចាំតំបន់

**ទស្សនវិស័យ**

ស្ត្រី និងកុមារី រស់នៅដោយសន្តិភាព សុវត្ថិភាព និងសេចក្តីថ្លៃថ្នូរ ហើយរីករាយនឹងសិទ្ធិមនុស្សជាសកលរបស់ខ្លួន។

**បេសកម្ម**

ពង្រឹងសិទ្ធិអំណាចដល់ស្ត្រី និងកុមារីឲ្យទាមទារសិទ្ធិជាសកលរបស់ខ្លួន ដើម្បីទទួលបាននូវសុវត្ថិភាពផ្ទាល់ខ្លួន និងចូលរួមដោយស្មើភាពគ្នាក្នុងការងារសហគមន៍ សង្គមស៊ីវិល ការអភិវឌ្ឍន៍សេដ្ឋកិច្ច និងចូលរួមក្នុងសកម្មភាពនយោបាយ សង្គម និងវប្បធម៌។

**ទិសដៅរួម**

ចូលរួមពង្រឹងសិទ្ធិអំណាចដល់ស្ត្រី និងកុមារីដែលរងគ្រោះ និងងាយរងគ្រោះ តាមរយៈការទប់ស្កាត់ ការការពារ និងការតស៊ូមតិ ដើម្បីលើកកម្ពស់ឲ្យមានសង្គមមួយដែលមាន សន្តិភាព សមភាពយេនឌ័រ និងក្តីមេត្តា ករុណា។

**តម្លៃស្នូល**

**សេចក្តីថ្លៃថ្នូរ៖** មនុស្សគ្រប់រូប ដោយមិនគិតពីឋានៈ ភេទ អសមត្ថភាព និងភាពខុសប្លែកដទៃទៀត គឺត្រូវរស់នៅប្រកបដោយសេចក្តីថ្លៃថ្នូរ។

**ភាពយុត្តិធម៌៖** មនុស្សគ្រប់រូប គួរតែរីករាយ និងទទួលបាននូវសិទ្ធិស្មើគ្នា នៅក្នុងការចូលរួមនៅក្នុងកិច្ចការនយោបាយ និងការអនុវត្ត ដែលអាចទទួលបាននូវការបែងចែកអំណាច ធនធាន និងឱកាសស្មើៗគ្នា។

**គណនេយ្យភាព៖** ធនធាន និងការទទួលខុសត្រូវ សម្រាប់ធ្វើការសម្រេចចិត្ត ត្រូវបានប្រើប្រាស់ជាមធ្យោបាយមួយ សម្រាប់ធ្វើឲ្យមានតម្លាភាព និងអាចឆ្លើយតបទៅនឹងម្ចាស់ជំនួយ ដែលស្របតាមធម្មនុញ្ញភាព ព្រមទាំងបំពេញតម្រូវការសហគមន៍។

**កម្មវិធីរបស់អង្គការ**

គោលដៅរួមរបស់អង្គការនឹងត្រូវបានសម្រេចឡើងតាមរយៈគោលដៅយុទ្ធសាស្ត្រចំនួនបួន៖

គោលបំណងយុទ្ធសាស្ត្រទី១: កម្មវិធីទប់ស្កាត់

គោលបំណងយុទ្ធសាស្ត្រទី២: កម្មវិធីការពារ

គោលបំណងយុទ្ធសាស្ត្រទី៣: កម្មវិធីតស៊ូមតិ

គោលបំណងយុទ្ធសាស្ត្រទី៤: ការអភិវឌ្ឍន៍អង្គការ

## ១. កម្មវិធីទប់ស្កាត់

### ១.១ គម្រោងរៀបចំសហគមន៍

ការអប់រំ នឹងពង្រឹងសិទ្ធអំណាចដល់ប្រជាពលរដ្ឋក្នុងសហគមន៍ មន្ត្រីមានកាតព្វកិច្ច អ្នកដឹកនាំសហគមន៍ និងអាណាព្យាបាល ដើម្បីផ្លាស់ប្តូរអាកប្បកិរិយារបស់ពួកគាត់ទាក់ទងនឹងសិទ្ធស្ត្រីនិងកុមារ គឺជាយុទ្ធសាស្ត្រមួយក្នុងចំណោមយុទ្ធសាស្ត្រផ្សេងៗទៀតរបស់អង្គការCWCC ក្នុងការដោះស្រាយបញ្ហាអំពើហិង្សាទាក់ទងនឹងយេនឌ័រនៅកម្ពុជា។ គម្រោងរៀបចំសហគមន៍បាន ផ្តល់ការកសាងសម្ថភាពដល់មន្ត្រីមានកាតព្វកិច្ចដែលរួមមាន អ្នកដឹកនាំសហគមន៍ អាជ្ញាធរមូលដ្ឋាន និងមន្ត្រីប៉ូលីស អំពីសិទ្ធស្ត្រី សិទ្ធរបស់ជនពិការ អំពើហិង្សាទាក់ទងយេនឌ័រ ច្បាប់អំពើហិង្សាក្នុងគ្រួសារ ច្បាប់ប្រឆាំងការជួញដូរ និងលើកកំពស់ការយល់ដឹងដល់ប្រជាពលរដ្ឋក្នុងសហគមន៍ ។

ក្នុងឆ្នាំ ២០២២ គម្រោងបានបន្តធ្វើការដោយផ្ទាល់ជាមួយក្រុមគាំទ្រស្ត្រីចំនួន៨ក្រុមដែលមានសមាជិកចំនួន ១២៧ នាក់ និងក្រុមការងារឆ្លើយតបអំពើហិង្សាទាក់ទងយេនឌ័រចំនួន៤ក្រុម ក្នុងស្រុកគងពិសី និងសំរោងទងខេត្តកំពង់ស្ពឺ និងស្រុកអង្គរធំ និងបន្ទាយស្រីខេត្តសៀមរាប ដែលមានសមាជិកសរុបចំនួន ១៧៧នាក់ (ស្ត្រី៦៩នាក់) ។ ក្រុមទាំងអស់បានដើរតួរនាទីជាភ្នាក់ងារសម្រាប់ធ្វើអោយមានការផ្លាស់ប្តូរនៅក្នុងសហគមន៍របស់ពួកគេរៀងៗខ្លួន តាមរយៈការលើកកំពស់ការយល់ដឹងទៅដល់ប្រជាពលរដ្ឋក្នុងសហគមន៍ ប្រមាណជា ១១០០ នាក់ ដែលក្នុងនោះ៧៨%ជាស្ត្រី ។

### ១.២ គម្រោងគ្រប់គ្រងកំហឹងបុរស

គម្រោងបានជ្រើសរើសបណ្តុះបណ្តាល និងធ្វើការដោយផ្ទាល់ជាមួយបុរសដែលជាមិត្តអប់រំមិត្ត ចំនួន ៧១នាក់ ក្នុងការផ្តល់ការប្រឹក្សាទៅដល់បុរសដែលប្រឈមនឹងការប្រព្រឹត្តអំពើហិង្សាចំនួន ៩៤នាក់ និងលើកកម្ពស់ការយល់ដឹងទៅដល់ពលរដ្ឋក្នុងសហគមន៍ចំនួន ៣៣៦នាក់ (ស្ត្រី៣១៥នាក់) នៅស្រុកអង្គរធំ ស្រុកសូទ្រនិគម និងស្រុកស្វាយលើ ខេត្តសៀមរាប ។

គម្រោងក៏បានអនុវត្តសកម្មភាពស្រដៀងគ្នានេះក្នុងការសម្របសម្រួលអាណាព្យាបាល ដើម្បីបង្កើតជាក្រុមឪពុកម្តាយគំរូ និងផ្តល់អោយពួកគាត់នូវវគ្គបណ្តុះបណ្តាលនានាអំពីឪពុកម្តាយគំរូ ដែលមានដូចជាភាពជាឪពុកម្តាយ តួរនាទីនិងការទទួលខុសត្រូវ ការប្រើប្រាស់ពេលវេលាសម្រាប់កូន គុណតម្លៃវិន័យជាវិជ្ជមាន ការធ្វើទំនាក់ទំនងល្អក្នុងគ្រួសារ សន្តិភាពក្នុងគ្រួសារ ការការពារកុមារ និងការរៀបចំថវិកាគ្រួសារ ។ ស្របពេលនៃការផ្តល់វគ្គបណ្តុះបណ្តាលនេះ គម្រោងក៏បានកសាងនូវភាពជឿជាក់ដល់ក្រុម និងបានជម្រុញទឹកចិត្តអោយពួកគាត់ក្លាយជាឪពុកម្តាយល្អដែលគោរពទៅតាមសិទ្ធិកុមារ ។ បច្ចុប្បន្នមានក្រុមឪពុកម្តាយគំរូចំនួន១២ក្រុម ដែលមានសមាជិក ២៥៦នាក់ ។ ដោយមានការកើនឡើងនូវការយល់ដឹងអំពីភាពជាឪពុកម្តាយគំរូ ក្រុមឪពុកម្តាយគំរូបានលើកកំពស់ការយល់ដឹងទៅដល់ពលរដ្ឋក្នុងសហគមន៍ចំនួន ៣៩៧នាក់ (ស្ត្រី៣៨៣នាក់) ។ ក្រុមគាំទ្រកុមារបច្ចុប្បន្នមានចំនួន ១០ក្រុម ដែលមានសមាជិក១៩៦នាក់ (ស្រី៣៧នាក់)។ ក្រុមគាំទ្រកុមារទាំង១០ក្រុមនេះបានចែករំលែក ចំណេះដឹងដែលពួកគេទទួលបានពីការកសាងសម្ថភាពដែលគម្រោងបានផ្តល់អោយកាន់មិត្តភក្រ តាមរយៈ ការផ្តល ប្រឹក្សាទៅដល់មិត្តភក្ររបស់ពួកគេ ។

### ១.៣ គម្រោងលើកកម្ពស់ការអប់រំរបស់ក្មេងស្រី

គម្រោងបានផ្តល់កញ្ចប់អាហារូបករណ៍ទៅដល់កុមារីងាយរងគ្រោះ ដែលក្នុងនោះរួមមាន កុមារីមកពីគ្រួសារក្រីក្រ កុមារីដែលមានអំពើហិង្សាក្នុងគ្រួសារ និងកុមារីដែលប្រឈមមុខនឹងការបោះបង់ចោលការសិក្សា នៅក្នុងតំបន់គោលដៅនៃខេត្តសៀមរាប រាជធានីភ្នំពេញ និងកំពង់ធំ។ ក្នុងឆ្នាំ២០២២ គម្រោងបានផ្តល់កញ្ចប់អាហារូបករណ៍ទៅដល់ក្មេងស្រីចំនួន២០០ នាក់ចាប់ពីកំរិតអនុវិទ្យាល័យ ដល់កំរិតវិទ្យាល័យ (ក្មេងស្រី ១០០នាក់ក្នុងខេត្តសៀមរាប និង១០០ នាក់ក្នុងរាជធានីភ្នំពេញ) ។ គម្រោងបានធ្វើការសហការណ៍ជាមួយក្រុមការងារអប់រំថ្នាក់មូលដ្ឋាន និង ក្រុមសម្របសម្រួលថ្នាក់ស្រុកក្នុងការជ្រើសរើសក្មេងស្រីអាហារូបករណ៍ និងផ្តល់កញ្ចាប់អាហារូបករណ៍ដើម្បីគាំទ្រការសិក្សារបស់ពួកគេ ។ កញ្ចប់អាហារូបករណ៍ដែលគម្រោងបានផ្តល់ជូនរួមមាន សម្ភារៈសិក្សារ ឯកសណ្ឋានសិស្ស កង់ ប្រាក់ឧបត្ថមប្រចាំខែ ប្រាក់សម្រាប់រៀនគួរក្រៅម៉ោង វគ្គបណ្តុះបណ្តាលកំព្យូទ័រ និងភាសារអង់គ្លេស។ ការផ្តល់ជូនទាំងនេះបានជួយ សម្រួលអោយក្មេងស្រីបន្តការសិក្សា និងទៅរៀនបានទៀងទាត់ ។ ក្មេងស្រីដែលមកពីគ្រួសារក្រីក្រ អាចមាន លទ្ធភាពក្នុងការរៀនសូត្រ និងបន្តការសិក្សារបស់ខ្លួនទៅកាន់វគ្គបណ្តុះបណ្តាលជំនាញផ្សេងៗ តាមរយៈកញ្ចប់អាហារូបករណ៍ និងបណ្តាញរបស់គម្រោងជាមួយសាលាជំនាញបណ្តុះបណ្តាលវិជ្ជាជីវៈនានា ។

### ១.៤ គម្រោងពង្រឹងសមត្ថភាពផ្នែកសេដ្ឋកិច្ចដល់ស្ត្រី

កម្មវិធីពង្រឹងសមត្ថភាពផ្នែកសេដ្ឋកិច្ចដល់ស្ត្រីមានគោលបំណង ផ្តល់សិទ្ធអំណាចដល់ស្ត្រី និងក្មេងស្រីដែលរស់នៅក្នុងតំបន់គោលដៅ ដើម្បីអោយពួកគាត់មានជីវភាពរស់នៅល្អប្រសើរ ជាមួយនឹងបណ្តាញសង្គមដ៏រឹងមាំមួយដើម្បីជួយអោយពួកគាត់យកឈ្នះលើបញ្ហាហិរញ្ញវត្ថុ និង កាត់បន្ថយភាពងាយរងគ្រោះពីរាល់ទម្រង់នៃអំពើហិង្សា ។ ក្នុងឆ្នាំ២០២២ គម្រោងបានធ្វើការជាមួយក្រុមសន្សំ៧០ក្រុម ដែលក្នុងនោះមាន ៤៥ក្រុមក្នុងខេត្តសៀមរាប ២៤ក្រុមក្នុងខេត្តកំពង់ធំ និង៣ក្រុមក្នុងខេត្តបន្ទាយមានជ័យ។ ក្រុមទាំងអស់មានសមាជិកសរុបចំនួន ២៣០០នាក់ (ស្ត្រី១៩២០នាក់)។ ក្រៅពីនេះគម្រោងក៏បានបន្តគាំទ្រដល់ក្រុមស្ត្រីធ្វើអាជីវកម្ម និងប្រកបមុខរបរផ្សេងៗ ក្នុងគោលបំណងជួយអោយពួកគាត់មានជំនាញ និងអាចរកប្រាក់ចំណូលសម្រាប់ផ្គត់ផ្គង់ខ្លួនឯង និងគ្រួសារ ។

បន្ថែមលើនេះទៅទៀត ក្រុមសហព័ន្ធចំនួន៣ក្នុងខេត្តសៀមរាប (២ក្រុមនៅស្រុកក្រឡាញ់ និង១ក្រុមនៅស្រុកសៀមរាប) និងក្រុមសហព័ន្ធ៣ក្រុមផ្សេងទៀតក្នុងខេត្តកំពង់ធំ (ស្រុកប្រាសាទសំបូរ ស្រុកសន្ទុក និងស្រុកប្រាសាទបាល័ង្គ) ដែលបច្ចុប្បន្នកំពុងដំណើរការយ៉ាងល្អ ។ ក្រុមសហព័ន្ធមានកាតព្វកិច្ចក្នុងការជួយសម្របសម្រួលក្រុមសន្សំអោយមានដំណើរ ការទៅមុខល្អប្រសើរ និងប្រកបដោយប្រសិទ្ធភាព។ ក្រុមសហព័ន្ធទាំងអស់ត្រូវបានទទួល ស្គាល់ដោយអាជ្ញាធរមូលដ្ឋាន ហើយបានរៀបចំរបាយ ការណ៍ទៅដល់អាជ្ញាធរមូលដ្ឋានជាប្រចាំ ។

បន្ថែមពីនេះទៀត កម្រោងបានសម្របសម្រួលយុវជនក្នុងការចូលរៀនជំនាញបច្ចេកទេស និងវិជ្ជាជីវៈបានចំនួន ១១១នាក់ (ស្រី៧១នាក់) ក្នុងនោះនៅវិទ្យាស្ថានពហុបច្ចេកទេសភូមិភាគតេជោសែន ៧៧នាក់ (ស្រី៣៩នាក់) នៅវិទ្យាស្ថានអភិវឌ្ឍន៍ស្ត្រី ២០នាក់ស្រី និងនៅអង្គការដៃគូរ ១៤នាក់ (ស្រី ១២នាក់)។ ក្នុងចំណោមសិស្សទាំងអស់ ៣៤នាក់ (ស្រី២១នាក់) បានបញ្ចប់ការសិក្សានិងមានការងារធ្វើតាមក្រុមហ៊ុនអង្គការ និងបង្កើតមុខរបរផ្ទាល់ខ្លួន។

### ១.៥ គម្រោងចំណាកស្រុកសុវត្ថិភាព និងទប់ស្កាត់ការជួញដូរមនុស្ស

គម្រោងបានអនុវត្តន៍នៅតំបន់គោលដៅ ក្នុងខេត្តបន្ទាយមានជ័យ និងរាជធានីភ្នំពេញ ក្នុងគោលបំណងលើកកម្ពស់ចំណេះដឹងស្តីពីការធ្វើចំណាកស្រុកមានសុវត្ថិភាព ការការពារ សិទ្ធិមនុស្ស ដែលរួមមានសិទ្ធរបស់ពលករចំណាកស្រុក (រួមបញ្ចូលទាំងស្ត្រី និងកុមារ) និងបង្ការភាពងាយរងគ្រោះនៃការកេងប្រវ័ញ្ចកម្លាំងពលកម្ម និងការជួញដូរមនុស្ស។ គម្រោងបានបន្តធ្វើការជាមួយក្រុមជួយខ្លួនឯងចំនួន២៩ក្រុម មានសមាជិកសរុបចំនួន២៨៥នាក់ (ស្ត្រី៧០ភាគរយ) ដែលពួកគេទាំងអស់សុទ្ធសឹងជាឪពុកម្តាយ របស់ពលករចំណាកស្រុក អតីតពលករចំណាកស្រុក និង ប្រជាជនមូលដ្ឋាន ។

ក្នុងឆ្នាំ២០២២ គម្រោងបានធ្វើការផ្សព្វផ្សាយចំណេះដឹងស្តីពីការធ្វើចំណាកស្រុកមានសុវត្ថិភាព និងទប់ស្កាត់ការជួយដូរមនុស្សទៅកាន់ប្រជាជនក្នុងសហគមន៍សរុបចំនួន ៣៧៧៣នាក់ (ស្ត្រី២៧៨៥នាក់)។

## ២. កម្មវិធីការពារ

### ២.១ គម្រោងលើកកម្ពស់បណ្តាញសហគមន៍ ដើម្បីការពារស្ត្រីនិងកុមារពីរាល់ទម្រង់នៃអំពើហិង្សា

គម្រោងបានរៀបចំវគ្គបណ្តុះបណ្តាលដល់សមាជិកបណ្តាញចម្រុះថ្នាក់ស្រុក ដែលពួកគាត់សុទ្ធសឹងតែជាមន្ត្រីមកពីការិយាល័យកិច្ចការនារី ការិយាល័យសង្គមកិច្ច គណៈកម្មាការទទួលបន្ទុកស្ត្រីនិងកុមារ បុគ្គលិកមណ្ឌលសុខភាព ប៉ូលីស និង បុគ្គលដែលជាធនធានសហគមន៍ ដែលមានស្រាប់ក្នុងរាជធានីភ្នំពេញ ខេត្តសៀមរាប និងខេត្តកំពង់ធំ ។ ជាលទ្ធផល ក្រុមបណ្តាញចម្រុះថ្នាក់ស្រុក បានជួយដោះស្រាយវិវាទចំនួន៣៣៥ករណី ក្នុងចំណោមករណីទាំងនេះមាន៣១៣ករណីជាករណីអំពើរហិង្សាក្នុងគ្រួសារ និង២២ករណីរំលោភបំពានផ្លូវភេទ។ ក្នុងនោះ២១៣ករណីករណីហិង្សារក្នុងគ្រួសារបានសះជា ៥៥ករណីលែងលះ ២០ករណីរំលោភបំពានផ្លូវភេទបញ្ជូនទៅប៉ូលី ១៤ករណីហិង្សាក្នុងគ្រួសារ និង២ករណីរំលោភបំពានផ្លូវភេទបញ្ជូនទៅ CWCC និង៣១ករណីករណីហិង្សារក្នុងគ្រួសារកំពុងស្ថិតក្នុងដំណើរការដោះស្រាយ។ តាមរយៈការអន្តរាគមន៍នេះស្ត្រី និងកុមារដែលជាជនរងគ្រោះនៃអំពើហិង្សាបាន ទទួលសេវាដែលសមស្រប និងឆ្លើយតបទៅតាមតម្រូវការរបស់ពួកគេ ។

### ២.២ គម្រោងជំនួយផ្នែកច្បាប់

ក្នុងឆ្នាំ ២០២២ មានករណីអំពើហិង្សាទាក់ទងយេនឌ័រចំនួន ៤៤២ករណីដែលមានសាច់ញាត្តិចំនួន១៥៤នាក់បានទទួលសេវាកម្មពីការិយាល័យអង្គការកម្ពុជាដើម្បីជួយស្ត្រីមានវិបត្តិ ក្នុងរាជធានីភ្នំពេញ ខេត្តសៀមរាប ខេត្តបន្ទាយមានជ័យ និង ខេត្តកំពង់ធំ ។ ក្នុងចំណោមករណីទាំងនោះ មាន២៤៥ជាករណីអំពើហិង្សាក្នុងគ្រួសារ ១០៣ជាករណីរំលោភបំពានផ្លូវភេទ និង ៩៤ជាករណីជួញដូរមនុស្ស ។

**ទិន្នន័យករណីអំពើហិង្សាទាក់ទងយេនឌ័រ ឆ្នាំ ២០២២**

| ករណី | ភ.ព | ប.ជ | ស.រ | ក.ធ | សរុប |
|---|---|---|---|---|---|
| អំពើហិង្សាក្នុងគ្រួសារ | ៤៦ | ៣៥ | ៩៤ | ៧០ | **២៤៥** |
| ការរំលោភបំពានផ្លូវភេទ | ១១ | ៣៦ | ៤៧ | ៩ | **១០៣** |
| ការជួញដូរមនុស្ស | ៩៣ | ១ | ០ | ០ | **៩៤** |

| | | | | | |
|---|---|---|---|---|---|
| **សរុប** | **១៥០** | **៧២** | **១៤១** | **៧៩** | **៤៤២** |

*ចំណាំ៖ ភ.ព=ភ្នំពេញ ប.ជ=បន្ទាយមានជ័យ ស.រ=សៀមរាប ក.ធ=កំពង់ធំ*

សម្រាប់ដំណើរការនៃការទទួលករណី ៣៥%នៃជនរងគ្រោះមកទទួលសេវាពីអង្គការ CWCC ដោយខ្លួនឯង និ៥៤%ត្រូវបានបញ្ជូនមកកាន់អង្គការ ។ ១១%ត្រូវបានជួយសង្គ្រោះ ដោយមានការចូលរួមពីអង្គការ CWCC ។

**ភាគរយនៃចំនួនអតិថិជនដែលមកទទួលសេវាពីអង្គការ cwcc ឆ្នាំ២០២២**




គម្រោងជំនួយផ្នែកច្បាប់បានផ្តល់ការប្រឹក្សាផ្នែកច្បាប់ និងគាំទ្រជនរងគ្រោះដែលសម្រេចចិត្តដាក់ពាក្យបណ្តឹងទៅកាន់តុលាការ តាមរយៈការជួយបំពេញឯកសារពត៌មានពាក្យបណ្តឹង និងស្វែងរកភស្តុតាងនានាដូចជាការសម្របសម្រួលក្នុងការធ្វើកោសល្យវិច្ច័យនៅមន្ទីពេទ្យ ។ ក្នុងចំណោមជនរងគ្រោះទាំងអស់ដែលមកស្វែងរកជំនួយពីអង្គការCWCCក្នុងឆ្នាំ២០២២ មានជនរងគ្រោះចំនួន២៥០នាក់ស្នើរសុំជំនួយផ្នែកច្បាប់ដែលករណីរបស់ពួកគេត្រូវបានបញ្ជូនទៅកាន់តុលាការរាជធានី និងខេត្ត ។ ជាលទ្ធផលឆ្នាំ២០២២ មាន១៨៩ករណីត្រូវបានបញ្ចប់តាមដំណើរការផ្លូវច្បាប់របស់តុលាការ ។ ក្នុងចំណោមទាំង១៨៩ ករណីនោះ មាន៨៧ករណីដែលជនប្រប្រិត្តបទល្មើសត្រូវកាត់ទោសអោយជាប់ពន្ធធានាគារ (៨៥ករណីជាករណីរំលោភបំពានផ្លូវភេទ ១ករណីជាករណីជួញដូរមនុស្ស និង១ករណីជាករណីអំពើហិង្សាក្នុងគ្រួសារ) ។

**ទិន្នន័យករណីអំពើហិង្សាទាក់ទងយេឌ័រដែលដាក់ពាក្យបណ្តឹងទៅតុលាការ ឆ្នាំ២០២២**

| **ករណី** | ករណីក្រោមអាយុ១៨ឆ្នាំ | | | | | ករណីលើអាយុ១៨ឆ្នាំ | | | | | **សរុបរួម** |
|---|---|---|---|---|---|---|---|---|---|---|---|
| | ភ.ព | ប.ជ | ស.រ | ក.ធ | **សរុប** | ភ.ព | ប.ជ | ស.រ | ក.ធ | **សរុប** | |
| អំពើហិង្សាក្នុងគ្រួសារ | ០ | ០ | ០ | ០ | ០ | ២៥ | ១២ | ៧៤ | ៣៤ | ១៤៥ | **១៤៥** |

| | | | | | | | | | | | |
|---|---|---|---|---|---|---|---|---|---|---|---|
| វិលោភបំពានផ្លូវភេទ | ៤ | ៣៣ | ៣៥ | ៦ | ៧៨ | ១ | ៣ | ១៩ | ៣ | ២៦ | **១០៤** |
| ការជួញដូរមនុស្ស | ០ | ០ | ០ | ០ | ០ | ០ | ១ | ០ | ០ | ១ | **១** |
| **សរុប** | **៤** | **៣៣** | **៣៥** | **៦** | **៧៨** | **២៦** | **១៦** | **៩៣** | **៣៧** | **១៧២** | **២៥០** |

*ចំណាំ៖ ភ.ព=ភ្នំពេញ ប.ជ=បន្ទាយមានជ័យ ស.រ=សៀមរាប ក.ធ=កំពង់ធំ*

**ទិន្នន័យករណីអំពើហិង្សាទាក់ទងយេឌ័រដែលបានជំនុំជម្រះ ឆ្នាំ២០២២**

| ករណី | ភ.ព | ប.ជ | ស.រ | ក.ធ | សរុប |
|---|---|---|---|---|---|
| អំពើហិង្សាក្នុងគ្រួសារ | ២៤ | ០ | ៦៥ | ១ | **៩០** |
| វិលោភបំពានផ្លូវភេទ | ១៤ | ១៧ | ៦០ | ៧ | **៩៨** |
| ការជួញដូរមនុស្ស | ១ | ០ | ០ | ០ | **១** |
| **សរុប** | **៣៩** | **១៧** | **១២៥** | **៨** | **១៨៩** |

*ចំណាំ៖ ភ.ព=ភ្នំពេញ ប.ជ=បន្ទាយមានជ័យ ស.រ=សៀមរាប ក.ធ=កំពង់ធំ*

**ទិន្នន័យជនប្រព្រឹត្តបទល្មើសដែលបានបញ្ជូនទៅកាន់ពន្ធធានាគា ឆ្នាំ២០២២**

| ករណី | ភ.ព | ប.ជ | ស.រ | ក.ធ | សរុប |
|---|---|---|---|---|---|
| អំពើហិង្សាក្នុងគ្រួសារ | ០ | ០ | ០ | ១ | **១** |
| វិលោភបំពានផ្លូវភេទ | ១៤ | ១៦ | ៥០ | ៥ | **៨៥** |
| ការជួញដូរមនុស្ស | ១ | ០ | ០ | ០ | **១** |
| សរុប | **១៥** | **១៦** | **៥០** | **៦** | **៨៧** |

*ចំណាំ៖ ភ.ព=ភ្នំពេញ ប.ជ=បន្ទាយមានជ័យ ស.រ=សៀមរាប ក.ធ=កំពង់ធំ*

### ២.៣ មណ្ឌលសុវត្ថិភាព

អតិថិជនដែលបានស្នាក់នៅក្នុងមណ្ឌលសុវត្ថិភាពរបស់អង្គការ CWCC ក្នុងរាជធានីភ្នំពេញ ខេត្តសៀមរាប និង ខេត្តបន្ទាយមានជ័យក្នុងឆ្នាំ២០២២ មានចំនួនសរុប២១៩នាក់ (ដែលក្នុងនោះមានជនរងគ្រោះ១៦៦នាក់ និង សាច់ញាត្តិ៥៣នាក់) ។ ក្នុងចំណោមពួកគេទាំងអស់ មានអតិថិជនអាយុក្រោម១៨ឆ្នាំចំនួន៨៨នាក់ (៥២នាក់ជាជនរងគ្រោះ និង ៣៦នាក់ជាសាច់ញាត្តិ)។ ក្នុងកំឡុងពេលនៃការស្នាក់នៅក្នុងមណ្ឌលសុវត្ថិភាពជនរងគ្រោះទទួលបានការប្រឹក្សាជាបុគ្គល និងជាក្រុម ដើម្បីកសាងទំនុកចិត្ត និងភាពជឿជាក់លើខ្លួនឯង ។ អតិថិជនក៏ទទួលបានវគ្គ បណ្តុះបណ្តាលជំនាញវិជ្ជាជីវៈ ដូចជាជំនាញកាត់ដេរ ចំអិនម្ហូប ធ្វើនំ ផាត់មុខ ធ្វើសក់ និងថ្នាក់អក្ខរកម្មផងដែរ ។ បន្ថែមពីនេះទៅទៀត អតិថិជនដែលមិនទាន់គ្រប់អាយុ បានបញ្ជូនអោយទៅសិក្សានៅសាលារដ្ឋដែលនៅជិតមណ្ឌល ហើយកុមារតូចៗដែលមានអាយុក្រោម៥ឆ្នាំទទួលបាន សេវាថែទាំប្រចាំថ្ងៃ។

**ចំនួនជនរងគ្រោះដែលបានស្នាក់នៅក្នុងមណ្ឌលសុវត្ថិភាពអង្គការ CWCC ឆ្នាំ២០២២**

| ជនរងគ្រោះ | អាយុក្រោម ១៨ឆ្នាំ | | | | អាយុលើ ១៨ឆ្នាំ | | | | សរុបរួម |
|---|---|---|---|---|---|---|---|---|---|
| | ភ.ព | ប.ជ | ស.រ | សរុប | ភ.ព | ប.ជ | ស.រ | សរុប | |
| អំពើហិង្សាក្នុងគ្រួសារ | ០ | ៣ | ០ | ៣ | ៦ | ៨ | ២ | ១៦ | **១៩** |
| រំលោភបំពានផ្លូវភេទ | ១ | ២៣ | ២០ | ៤៤ | ១ | ០ | ៦ | ៧ | **៥១** |
| ការជួញដូរមនុស្ស | ៤ | ១ | ០ | ៥ | ៨៩ | ២ | ០ | ៩១ | **៩៦** |
| **សរុប** | **៥** | **២៧** | **២០** | **៥២** | **៩៦** | **១០** | **៨** | **១១៤** | **១៦៦** |
| | អាយុក្រោម ១៨ឆ្នាំ | | | | អាយុលើ ១៨ឆ្នាំ | | | | |
| **សាច់ញាត្តិ** | ភ.ព | ប.ជ | ស.រ | សរុប | ភ.ព | ប.ជ | ស.រ | សរុប | **សរុបរួម** |
| អំពើហិង្សាក្នុងគ្រួសារ | ៥ | ១៤ | ០ | ១៩ | ០ | ០ | ៦ | ៦ | **២៥** |
| រំលោភបំពានផ្លូវភេទ | ០ | ៥ | ១០ | ១៥ | ១ | ៤ | ៤ | ៩ | **២៤** |
| ការជួញដូរមនុស្ស | ២ | ០ | ០ | ២ | ២ | ០ | ០ | ២ | **៤** |
| **សរុប** | **៧** | **១៩** | **១០** | **៣៦** | **៣** | **៤** | **១០** | **១៧** | **៥៣** |
| **សរុបរួម** | **១២** | **៤៦** | **៣០** | **៨៨** | **៩៩** | **១៤** | **១៨** | **១៣១** | **២១៩** |

*ចំណាំ៖ ភ.ព=ភ្នំពេញ ប.ជ=បន្ទាយមានជ័យ ស.រ=សៀមរាប*

### ២.៤ គម្រោងសមាហរណកម្ម

ក្នុងឆ្នាំ២០២២ បន្ទាប់ពីករណីរបស់ជនរងគ្រោះត្រូវបានបញ្ចប់នៅតុលាការ និងស្នាក់នៅមណ្ឌលមានជនរងគ្រោះចំនួន៧១នាក់និងសាច់ញាត្តិចំនួន៤១នាក់ ត្រូវបានធ្វើសមាហរណកម្មទៅតាមសហគមន៍ដែលពួកគេជ្រើសរើស។ ក្នុងចំណោមជនរងគ្រោះទាំងអស់ មានជនរងគ្រោះចំនួន៥៩នាក់ ទទួលបានជំនួយឧបត្ថមគាំទ្រជាថវិការ និងសម្ភារៈសម្រាប់ការរស់នៅ ហើយមានជនរងគ្រោះចំនួន៧នាក់ទទួលបានជំនួយឧបត្ថមគាំទ្រការធ្វើអាជីវកម្ម ដើម្បីធានាអោយបានការរស់នៅប្រកបដោយ ឯករាជ្យ និងនិរន្តរភាពហើយចៀសផុតពីអំពើហិង្សា និងបរិយាកាសងាយរងគ្រោះណាមួយ។ បុគ្គលិកគម្រោងនៅតែបន្ត តាមដានស្ថានភាពរបស់អតិថិជនដែលបានធ្វើសមាហរណកម្ម តាមរយៈការធ្វើទំនាក់ទំនងជាមួយអាជ្ញាធរក្នុងតំបន់ ការសួរសុខទុក្ខនៅផ្ទះអតិថិជន ដើម្បីធ្វើអោយប្រាកដថាបាននូវការធ្វើសមាហរណកម្មមានភាពជោគជ័យ ។

**ចំនួនអតិថិជនដែលបានធ្វើសមាហរណកម្មឆ្នាំ ២០២២**

| **ករណី** | ជនរងគ្រោះ | | | | | សាច់ញាត្តិ | | | | | **សរុបរួម** |
|---|---|---|---|---|---|---|---|---|---|---|---|
| | ភ.ព | ប.ជ | ស.រ | ក.ធ | សរុប | ភ.ព | ប.ជ | ស.រ | ក.ធ | សរុប | |
| អំពើហិង្សាក្នុងគ្រួសារ | ១ | ២ | ៥ | ១១ | ១៩ | ០ | ០ | ៣ | ១៨ | **២១** | **៤០** |
| រំលោភបំពានផ្លូវភេទ | ០ | ១៨ | ៤ | ១១ | ៣៣ | ០ | ៦ | ០ | ១៤ | **២០** | **៥៣** |
| ការជួញដូរមនុស្ស | ១៨ | ១ | ០ | ០ | ១៩ | ០ | ០ | ០ | ០ | **០** | **១៩** |

| | | | | | | | | | | |
|---|---|---|---|---|---|---|---|---|---|---|
| សរុប | ១៩ | ២១ | ៩ | ២២ | ៧១ | ០ | ៦ | ៣ | ៣២ | ៤១ | ១១២ |

*ចំណាំ៖ ភ.ព=ភ្នំពេញ ប.ជ=បន្ទាយមានជ័យ ស.រ=សៀមរាប ក.ធ=កំពង់ធំ*

# ៣. កម្មវិធីតស៊ូមតិ

## ៣.១ ការសហការណ៍ជាមួយរាជរដ្ឋាភិបាល

នៅថ្ងៃទី២៣ ខែមិនា ឆ្នាំ២០២២ តំណាងអង្គការកម្ពុជាដើម្បីជួយស្ត្រីមានវិបត្តិបានចូលរួមសិក្ខាសាលាសិក្ខាសាលាពិគ្រោះយោបល់ ដើម្បីពិនិត្យឡើងវិញនូវឯកសារគោលការណ៍ណែនាំ ស្តីពីដំណើការនៃការបង្កើត និងតួនាទីភារកិច្ចក្រុមឆ្លើយតបជាពហុវិស័យចំពោះអំពើហិង្សាទាក់ទងនឹងយេនឌ័រ ក្រោមការដឹកនាំក្រសួងកិច្ចការនារី។ សិក្ខាសាលាពិគ្រោះយោបល់នេះដឹកនាំដោយក្រសួងកិច្ចការនារី ក្រោមជំនួយពីរដ្ឋាភិបាលអូស្រ្តាលី តាមរយៈកម្មវិធី ACCESS ដែលមានអ្នកចូលរួមពីតំណាងក្រសួងមហាផ្ទៃ ក្រសួងកិច្ចការនារី គណៈកម្មាធិការសម្រាប់ ការអភិវឌ្ឍតាមបែបលិទ្ធិប្រជាធិបតេយ្យនៅថ្នាក់ក្រោមជាតិ អគ្គលេខាធិការដ្ឋានសកម្មភាពជនពិការ DFAT និងតំណាងអង្គការដៃគូមាន UNWomen UNFPA LAC CARE CWCC ក្រុមការងារកម្មវិធី ACCESS ចំនួន ៣០នាក់ (ស្រី២២នាក់) នៅសណ្ឋាគារកាំបូឌីយ៉ាណា។ គោលបំណងនៃកិច្ចប្រជុំ ដើម្បីប្រមូលធាតុចូលបន្ថែម និងកែសម្រួលឯកសារណែនាំស្តីពីការបង្កើតក្រុមការងារឆ្លើយតបជាពហុវិស័យចំពោះអំពើហិង្សាទាក់ទងនឹងយេនឌ័រ ឱ្យឯកសារនេះមានរចនាសម្ព័ន្ធរួមមួយងាយស្រួលក្នុងការអនុវត្ត។

នៅថ្ងៃទី២៨ ខែកញ្ញា ឆ្នាំ២០២២ តំណាងអង្គការកម្ពុជាដើម្បីជួយស្ត្រីមានវិបត្តិបានចូលរួមកិច្ចប្រជុំពិភាក្សា ស្តីពីតួនាទីសាសនា ក្នុងការទប់ស្កាត់និងឆ្លើយតបអំពើហិង្សាលើស្ត្រី ក្រោមអធិបតីភាពលោកជំទាវ ហ៊ូ សាមិត្ត រដ្ឋលេខាធិការក្រសួងកិច្ចការនារី ក្រោមកិច្ចសហការជាមួយអង្គការ UNFPA នៅសណ្ឋាគារ សាន់វេ រាជធានីភ្នំពេញ។ កិច្ចប្រជុំនេះមានគោលបំណង៖ លើកកម្ពស់ការយល់ដឹងពីអំពើហិង្សាលើស្ត្រី និងក្មេងស្រីដល់អ្នកដឹកនាំសាសនា ពិភាក្សាលើឧត្តមានុវត្តន៍បញ្ហាប្រឈម និងមេរៀនជាបទពិសោធន៍ទាក់ទងនិងការងារលើកកម្ពស់យេនឌ័រ និងការចូលរួមទប់ស្កាត់អំពើហិង្សាទាក់ទងនិងយេនឌ័រ កៀរគរនិងបង្កើនការចូលរួមរបស់សាសនា ជាពិសេសការប្តេជ្ញាចិត្តរបស់អ្នកដឹកនាំសាសនា ក្នុងការផ្សព្វផ្សាយដល់សាសនិកដើម្បចូលរួមទប់ស្កាត់អំពើហិង្សាលើស្ត្រី និងក្មេងស្រី កំណត់ទិសដៅ និងសកម្មភាពជាអាទិភាពជាក់លាក់សម្រាប់អនុវត្តក្នុងឆ្នាំ២០២៣ ទាក់ទងនិងតួនាទីរបស់អ្នកដឹកនាំសាសនា នៅក្នុងការចូលរួមលើកកម្ពស់សមភាពយេនឌ័រ និងការទប់ស្កាត់អំពើហិង្សាលើស្ត្រី។ កិច្ចប្រជុំនេះមានការចូលលរួមពីតំណាងក្រសួងកិច្ចការនារី តំណាងក្រុមការងារឆ្លើយតបអំពើហិង្សាទាក់ទងនឹងយេនឌ័រ តំណាងក្រសួងធម្មការនិងសាសនា តំណាងព្រះសង្ឃពុទ្ធសាសនាតំណាងគណៈអ៊ីម៉ាំ សាសនាឥស្លាម តំណាងគ្រឹស្ទ័សាសនាប្រមាណ៧០នាក់។

នៅថ្ងៃទី៣០ ខែកញ្ញា ឆ្នាំ២០២២ តំណាងអង្គការកម្ពុជាដើម្បីជួយស្ត្រីមានវិបត្តិបានចូលរួម កិច្ចប្រជុំក្រុមការងារបច្ចេកទេសឆ្លើយតបអំពើហិង្សាទាក់ទងនឹងយេនឌ័រលើកទី២៧ ក្នុងគោលបំណងតាមដានលើការអនុវត្តផែនការសកម្មភាពជាតិស្ដីពី ការទប់ស្កាត់អំពើហិង្សាលើស្ត្រី ២០១៩-២០២៣ និងចែករំលែកបទពិសោធន៍អំពីការផ្ដល់សេវា ទប់ស្កាត់ឆ្លើយតបអំពើហិង្សាទាក់ទងនឹងយេនឌ័រ និងការត្រៀមផែនការសកម្មភាពរៀបចំយុទ្ធនាការ១៦ថ្ងៃ ដើម្បីបញ្ឈប់អំពើហិង្សាលើស្ត្រីប្រចាំឆ្នាំ២០២២ រៀបចំដោយ ក្រសួងកិច្ចការនារី គាំទ្រពីអង្គការ UNWomen តាមរយៈកម្មវិធីACCESS ដោយមានការអញ្ជើញចូលរួមពីក្រសួងស្ថាប័នពាក់ពន្ធ័ អង្គការសង្គមស៊ីវិល និងអង្គការដៃគូរអភិវឌ្ឍន៍ សរុបប្រមាណ១០៦នាក់ ស្រី៧៣នាក់ នៅសណ្ឋាគារកាំបូឌីយ៉ាណា។

តំណាងអង្គការកម្ពុជាដើម្បីជួយស្ត្រីមានវិបត្តិបានចូលរួម ក្នុងកិច្ចប្រជុំក្រុមការងារបច្ចេកទេសឆ្លើយតបអំពើហិង្សាទាក់ទងនឹងយេនឌ័រលើកទី២៨ របស់ក្រសួងកិច្ចការនារី នៅថ្ងៃទី០៩ ខែធ្នូ ឆ្នាំ២០២២ ក្នុងគោលបំណង ពិភាក្សានិងពិគ្រោះយោបល់ក្នុងការវាយតម្លៃលើការអនុវត្តផែនការសកម្មភាពជាតិស្ដីពី ការទប់ស្កាត់អំពើហិង្សា លើស្ត្រី (NAP VAW III) ២០១៩-២០២៣ និងចូលរួមអបអរសាទរបញ្ចប់យុទ្ធនាការ១៦ថ្ងៃដើម្បីបញ្ឈប់អំពើ ហិង្សាលើស្ត្រី ក្រោមប្រធានបទ " រួមគ្នាធ្វើសកម្មភាពបញ្ឈប់អំពើហិង្សាលើស្ត្រីនិងក្មេងស្រី " ក្នុងឆ្នាំ២០២២។ សកម្មភាពនេះ មានការគាំទ្រពីអង្គការ UNWomen តាមរយៈកម្មវិធីACCESS និងថវិកាជាតិតាមកម្មវិធី ដែលមានការអញ្ជើញចូលរួមពីក្រសួងស្ថាប័នពាក់ពន្ធ័ អង្គការសង្គមស៊ីវិល និងអង្គការដៃគូរអភិវឌ្ឍន៍ សរុប ប្រមាណ១០៤នាក់ ស្រី៧០នាក់ នៅសណ្ឋាគារដារ៉ាអ៊ែរផត។

ថ្ងៃទី២៥ ខែមករា ឆ្នាំ២០២២ តំណាងអង្គការកម្ពុជាដើម្បីជួយស្ត្រីមានវិបត្តិបានចូលរួមកិច្ចប្រជុំពិនិត្យពិភាក្សា សៀវភៅគោលការណ៍ណែនាំ ស្តីពីបែបបទ និងនីតិវិធី នៃការកំណត់អត្តសញ្ញាណជនរងគ្រោះដោយអំពើជួញដូរមនុស្សដើម្បីផ្តល់សេវាសមស្រប (តាមរយៈហ្សូម) ក្រោមអធិបតីភាព លោកជំទាវ ជូ ប៊ុនអេង រដ្ឋលេខាធិការក្រសួងមហាផ្ទៃ និងជាអនុប្រធានអចិន្ត្រៃយ៍ គ.ជ.ប.ជ ដោយមានការចូលរួមពីចូលរួមពីក្រសួងស្ថាប័នពាក់ពន្ធ័ អង្គការសង្គមស៊ីវិល និងអង្គការដៃគូរអភិវឌ្ឍន៍។

នៅថ្ងៃ ទី២១ ខែកុម្ភៈ ឆ្នាំ២០២២ តំណាងអង្គការកម្ពុជាដើម្បីជួយស្ត្រីមានវិបត្តិបានចូលរួមសិក្ខាសាលាកែសម្រួលសៀវភៅគោលការណ៍ណែនាំ ស្តីពីការកំណត់អត្តសញ្ញាណជនរងគ្រោះ ដើម្បីផ្តល់សេវាសមស្របលើកទី២ នៅសណ្ឋាគារសាន់វ៉េភ្នំពេញ ក្រោមអធិបតីភាព លោកជំទាវ ជូ ប៊ុនអេង រដ្ឋលេខាធិការក្រសួងមហាផ្ទៃ និងជាអនុប្រធានអចិន្ត្រៃយ៍ គ.ជ.ប.ជ ដោយមានការចូលរួមពី ចូលរួមពីក្រសួងស្ថាប័នពាក់ពន្ធ័ អង្គការសង្គមស៊ីវិល និងអង្គការដៃគូរអភិវឌ្ឍន៍។

### ៣.២ យុទ្ធនាការស្វែងរកមតិគាំទ្រ

អង្គការកម្ពុជាដើម្បីជួយស្ត្រីមានវិបត្តិបានសហការជាមួយអាជ្ញាធរ និងអ្នកពាក់ព័ន្ធក្នុងការរៀបចំយុទ្ធនាការ១៦ថ្ងៃប្រឆាំងអំពើហិង្សាទាក់ទងនឹងយេនឌ័រ ក្រោមប្រធានបទ "រួមគ្នាធ្វើសកម្មភាពដើម្បីបញ្ឈប់អំពើហិង្សាលើស្ត្រីនិងក្មេងស្រី" ក្នុងគោលបំណង លើកកម្ពស់ការយល់ដឹងអំពីអំពើហិង្សាទាក់ទងនឹងយេនឌ័រ

និងបញ្ហាប្រឈមទាក់ទងនឹងឥរិយាបទពីសអើងលើស្រ្តី និងក្មេងស្រី និងលើកទឹកចិត្តឱ្យចូលរួមបញ្ឈប់អំពើហិង្សាទាក់ទងនឹងយេនឌ័រ ព្រមទាំងអំពាវនាវឱ្យមានការធ្វើឱ្យប្រសើរឡើងនូវការទទួលបានសេវានានារួមទាំងសេវាផ្លូវច្បាប់ ។ យុទ្ធនាការនេះបានប្រារព្ធឡើងនៅ៖

- ✓ ថ្ងៃទី២៨ ខែធ្នូ ឆ្នាំ២០២២ នៅស្រុកសន្ទុកខេត្តកំពង់ធំ ដោយមានអ្នកចូលរួមសរុប១៧០ (ស្រី១១៣នាក់)។
- ✓ ថ្ងៃទី២៩ ខែធ្នូ ឆ្នាំ២០២២ នៅស្រុកប្រាសាទសំបូរ ខេត្តកំពង់ធំ ដោយមានអ្នកចូលរួមសរុប១៧១ (ស្រី១២៧នាក់)។
- ✓ ថ្ងៃទី០៥ ខែធ្នូ ឆ្នាំ២០២២នៅស្រុកបាសាទបាល័ង្ក ដោយមានអ្នកចូលរួមសរុប១៩២នាក់ (ស្រី១៣៣នាក់)។
- ✓ ថ្ងៃទី០២ ខែធ្នូ ឆ្នាំ ២០២២ នៅវិទ្យាល័យជាស៊ីមចំរើនរដ្ឋខណ្ឌឬស្សីកែវ រាជធានីភ្នំពេញ មានអ្នកចូលរួមសរុបចំនួន ១៩៥ នាក់ (ស្រី១៣៤នាក់)។
- ✓ ថ្ងៃទី០៦ ខែធ្នូ ឆ្នាំ២០២២ នៅវត្តសែនដូនទាវ ស្រុកគងពិសី ខេត្តកំពង់ស្ពឺ ដែលមានអ្នកចូលរួមសរុបចំនួន១៨០ នាក់ (ស្រី ១៤០នាក់)។
- ✓ ថ្ងៃទី០៩ ខែធ្នូ ឆ្នាំ២០២២ នៅស្រុកអង្គរធំ ខេត្តសៀមរាប ដែលមានអ្នកចូលរួមសរុបចំនួន ១៧០នាក់ (ស្រី ១២៦នាក់)។

អង្គការកម្ពុជាដើម្បីជួយស្ត្រីមានវិបត្តិបានសហការជាមួយលេខាធិការដ្ឋាន ប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្សខេត្តកំពង់ធំដើម្បីរៀបចំប្រារព្ធធ្វើទិវាប្រឆាំងការជួញដូរមនុស្ស ១២ ធ្នូ នៅថ្ងៃទី ២៦ ខែធ្នូ ឆ្នាំ ២០២២ នៅសាលាខេត្តកំពង់ធំ ដែលមានអ្នកចូលរួមសរុបចំនួន ៣៨៩នាក់ (ស្រី២០៨នាក់) ដោយមានការចូលរួមពីមន្ទីរពាក់ព័ន្ធជុំវិញខេត្ត អភិបាលស្រុក អភិបាលរងស្រុកទាំងអស់ក្នុងខេត្តកំពង់ធំ អង្គការសង្គមស៊ីវិល យុវជនកាយរិទ្ធ និងយុវជនកាកបាទក្រហម។ យុទ្ធនាការ១២ធ្នូនេះ ប្រព្រឹត្តទៅក្រោមអធិបតីភាពដ៏ខ្ពង់ខ្ពស់ លោក ញឹក បានកេង អភិបាលរងខេត្ត ។ ទិវាជាតិប្រឆាំងការជួញដូរមនុស្ស ក្រោមប្រធានបទ «រួមគ្នាលុបបំបាត់អំពើរជួញដូរមនុស្សឆ្ពោះទៅសម្រេចគោលដៅអភិវឌ្ឍន៍ជាតិប្រកបដោយចីរភាព» ក្នុងគោលបំណងបង្ហាញពីឆន្ទៈដ៏មុតមាំរបស់រាជរដ្ឋាភិបាលកម្ពុជា អង្គការសង្គមស៊ីវិល និងប្រជាពលរដ្ឋទាំងអស់ក្នុងការរួមគ្នាទប់ស្កាត់ បង្ក្រាប ផ្តន្ទាទោស សង្គ្រោះ និងការពារប្រទេសកម្ពុជាពីការជួញដូរមនុស្សក ហើយក៏ជាការប្តេជ្ញាចិត្តរបស់រាជរដ្ឋាភិបាលក្នុងការសហការជាមួយដៃគូពាក់ព័ន្ធ និងទាមទារឱ្យមានកិច្ចសហប្រតិបត្តិការជាក់លាក់បន្ថែមទៀតពីប្រទេសពាក់ព័ន្ធក្នុងតំបន់ និងពិភពលោក ដើម្បីរួមគ្នាបង្ក្រាបការជួញដូរមនុស្សគ្រប់ទម្រង់ និងដាក់ទោសទណ្ឌជនល្មើស ដើម្បីកាត់បន្ថយ និងលុបបំបាត់នៃឧក្រិដ្ឋកម្ម។

# ៤. កម្មវិធីអភិវឌ្ឍន៍អង្គការ

## ៤.១ នាយកក្រុមប្រឹក្សាភិបាល

នាយកក្រុមប្រឹក្សាភិបាលនៃអង្គការកម្ពុជាដើម្បីជួយស្ត្រីមានវិបត្តិ មានប្រាំនាក់ដែលជាអ្នកដឹកនាំក្រុមអង្គការសិទ្ធិមនុស្សដ៏លេចធ្លោនៅកម្ពុជា៖ (១) ប្រធានក្រុមក្រុមប្រឹក្សាភិបាល លោកស្រ្តី គៀន សិរីផល

ជាអ្នកបង្កើត និងជាអតីតប្រធានអង្គការអភិវឌ្ឍន៍ស្ត្រីកម្ពុជា (CWDA) និងបច្ចុប្បន្នលោកស្រីជាអ្នកប្រឹក្សាឯករាជ (២) លោកមេធាវី សុក សំអឿន ជានាយកប្រតិបត្តិនៃក្រុមអ្នកច្បាប់ការពារសិទ្ធិកម្ពុជា ដែលជាអង្គការជំនួយផ្នែកច្បាប់ដ៏លេចធ្លោនៅក្នុងប្រទេសកម្ពុជា (៣) លោកស្រី លឹម ស៊ាវហុង ជាទីប្រឹក្សានៃអង្គការ Give2Asia ប្រចាំប្រទេសកម្ពុជា (៤) លោក ជា ពីដែន គឺជានាយកប្រតិបត្តិអង្គការគាំពារកុមារងាយទទួលរងគ្រោះ (VCAO) ដែលធ្វើការការពារសិទ្ធកុមារ និងលើកកម្ពស់ការចូលរួមរបស់កុមារ និង (៥) លោកស្រី ប៉ែន មនោរម្យ ដែលបច្ចុប្បន្នជានាយិការរងអង្គការ PSI ។ នៅចុងឆ្នាំ២០២២ អង្គការកម្ពុជាដើម្បីជួយស្ត្រីមានវិបត្តិ មានការផ្លាស់ប្តូរសមាជិកប្រុមប្រឹក្សាភិបាល នាយិកាប្រតិបត្តិ និងប្រធានគ្រប់គ្រងកម្មវិធី។ ថ្នាក់គ្រប់គ្រងអង្គការបានជូនដំណឹងអំពីការផ្លាសប្តូរនេះទៅក្រសួងមហាផ្ទៃរួចហើយ។

### ៤.២ បុគ្គលិករបស់អង្គការ

ក្នុងឆ្នាំ២០២២ បុគ្គលិកអង្គការ CWCC មានបបុគ្គលិកសរុបចំនួន៦០នាក់ (បុរស២១នាក់)។ បុគ្គលិកដែលនៅការិយាល័យកណ្តាលមាន៨នាក់ (ស្រី៤នាក់) ការិយាល័យភ្នំពេញ ១៦នាក់ (ស្រី១០នាក់) ការិយល័យខេត្តសៀមរាបមាន១៩នាក់ (ស្រី១៤នាក់) ការិយាល័យខេត្តបន្ទាយ មានជ័យមាន ១០នាក់ (ស្រី៦នាក់) ការិយាល័យខេត្តកំពង់ធំមាន៦នាក់ (ស្រី៤នាក់)។

### ៤.៣ ការកសាងសមត្ថភាពបុគ្គលិក

បុគ្គលិកអង្គការ CWCC បានទទួលការបបណ្តុះបណ្តាលដើម្បីលើកកម្ពស់សមត្ថភាពការងារ និងអភិវឌ្ឍបុគ្គលិកឆ្នាំ២០២១ មានដូចជា៖

១. វគ្គបណ្តុះបណ្តាលអំពី “ការដាក់ពាក្យប្តឹងនិងការបញ្ជូនជនរងគ្រោះ” រៀបចំដោយកម្មវិធីSafe and Fair របស់អង្គការ ILO កាលពីថ្ងៃទី ២៥ ខែ កុម្ភៈ ឆ្នាំ២០២២តាមប្រព័ន្ធZoom។

២. វគ្គបណ្តុះបណ្តាលអំពី “ការទំនាក់ទំនងជាមួយជនមានពិការភាព” រៀបចំដោយកម្មវិធីACCESS តាមប្រព័ន្ធZoom កាលពីថ្ងៃទី០២ ខែមីនា ឆ្នាំ២០២២។

៣. វគ្គបណ្តុះបណ្តាលអំពី “ការសម្របសម្រួលក្រៅប្រព័ន្ធតុលាការ” រៀបចំដោយកម្មវិធីACCESS នៅអូតែលតារាអ៊ែរផត កាលពីថ្ងៃទី១៨ ខែមីនា ឆ្នាំ២០២២។

៤. វគ្គបណ្តុះបណ្តាលអំពី “Do no harm” រៀបចំដោយអង្គការCCCនៅខេត្តកំពង់ធំ កាលពីថ្ងៃទី០៥ - ០៦ ខែ មេសា ឆ្នាំ២០២២។

៥. វគ្គបណ្តុះបណ្តាលអំពី “ការគ្រប់គ្រងហិរញ្ញវត្ថុសម្រាប់នារីចំណាកស្រុកក្នុងតំបន់អាស៊ី” រៀបចំដោយអង្គការCWCC នៅអូតែលភ្នំពេញ កាលពីថ្ងៃទី២៣ - ២៧ ខែ កញ្ញា ឆ្នាំ២០២២។

៦. វគ្គបណ្តុះបណ្តាលអំពី “ការវិភាគសង្គម” រៀបចំដោយអង្គការCARE Cambodia នៅអូតែល Sunway កាលពីថ្ងៃទី២០ - ២១ ខែ កក្កដា ឆ្នាំ២០២២។

៧. វគ្គបណ្តុះបណ្តាលអំពី “កុមារមានកិរិយាផ្លូវភេទបែបគ្រោះថ្នាក់” រៀបចំដោយអង្គការជំហានដំបូងកម្ពុជា នៅមន្ទីរពេទ្យកុមារអង្គរខេត្តសៀមរាប កាលពីថ្ងៃទី១៦ - ១៨ ខែឧសភា ឆ្នាំ២០២២។

៨. វគ្គបណ្តុះបណ្តាលអំពី “កិច្ចការពារកុមារប្រកបដោយបរិយាបន្ន” រៀបចំដោយអង្គការជំហានដំបូងកម្ពុជា នៅមន្ទីរពេទ្យកុមារអង្គរខេត្តសៀមរាប កាលពីថ្ងៃទី២០ - ២៣ ខែមិថុនា ឆ្នាំ២០២២។

៩. វគ្គបណ្តុះបណ្តាលអំពី “របៀបធ្វើការជាមួយគ្រួសារ” រៀបចំដោយ អង្គការ ជំហានដំបូងកម្ពុជា

នៅមន្ទីរពេទ្យកុមារអង្គរខេត្តសៀមរាប កាលពីថ្ងៃទី១៣ - ១៤ ខែកញ្ញា ឆ្នាំ២០២២។

១០. វគ្គបណ្តុះបណ្តាលអំពី "ការបង្កើតអង្គការសុវត្ថិភាពកុមារ" រៀបចំដោយកម្មវិធី ACFID ឧបត្ថម្ភដោយអង្គការ AOP តាមប្រព័ន្ធអេឡិចត្រូនិច កាលពីថ្ងៃទី១០ ខែតុលា ឆ្នាំ២០២២។

១១. វគ្គបណ្តុះបណ្តាលអំពី "ការគ្រប់គ្រងហានិភ័យសម្រាប់ការពារកុមារ" រៀបចំដោយកម្មវិធី ACFID ឧបត្ថម្ភដោយអង្គការ AOP តាមប្រព័ន្ធអេឡិចត្រូនិច កាលពីថ្ងៃទី០៤ ខែតុលា ឆ្នាំ២០២២។

១២. វគ្គបណ្តុះបណ្តាលអំពី "ការណែនាំអំពីការការពារកុមារនៅក្នុងផ្នែកអភិវឌ្ឍន៍អន្តរជាតិ" រៀបចំដោយកម្មវិធី ACFID ឧបត្ថម្ភដោយអង្គការ AOP តាមប្រព័ន្ធអេឡិចត្រូនិច កាលពីថ្ងៃទី០១ ខែធ្នូ ឆ្នាំ២០២២។

## របាយការណ៍ហិរញ្ញវត្ថុសង្ខេប

### ចរិកាហិរញ្ញវត្ថុ ២០២២

| Donors | Income | Percentage |
|---|---:|---:|
| Lotus Outreach | 140,242 | 16.24% |
| AOP | 56,338 | 6.53% |
| TDH-G | 26,890 | 3.11% |
| ACCESS | 146,343 | 16.95% |
| ACCESS GDI Training | 23,098 | 2.68% |
| FWC | 6,990 | 0.81% |
| FCA | 116,767 | 13.52% |
| ILO | 28,445 | 3.29% |
| SOLIDAR | 84,020 | 9.73% |
| ATIKHA | 32,897 | 3.81% |
| CARE | 114,518 | 13.26% |
| UNTF | 79,009 | 9.15% |
| Earth Tree/Jica/shelter renovation | 7,858 | 0.91% |
| **Grand Total** | **863,414** | **100.00%** |

### ការចំណាយហិរញ្ញវត្ថុ ២០២២



## ទំនាក់ទំនង៖

### ការិយាល័យកណ្តាល

- អាសយដ្ឋាន៖ #១៣C ផ្លូវ៣៣១ បឹងកក២ ទួលគោក ភ្នំពេញ កម្ពុជា
- អាសយដ្ឋានប្រៃសណីយ៖ PO Box ២៤២១
- ទូរស័ព្ទ៖ (៨៥៥-២៣) ៩៩៧៩៦៧
- អ៊ីម៉ែល៖ HOadmin@cwcc.org.kh
- វេបសាយ៖ www.cwcc.org.kh

### ការិយាល័យរាជធានីភ្នំពេញ

- អាសយដ្ឋាន៖ #៤២F ផ្លូវ៤៨៨ ផ្សាដើមថ្កូវ ចំការមន ភ្នំពេញ កម្ពុជា
- អាសយដ្ឋានប្រៃសណីយ៖ P.O Box ២៤២១ និង CCC box ៣៥៦
- ទូរស័ព្ទ៖ (៨៥៥-២៣) ៩៨៧១៥៨
- អ៊ីម៉ែល៖ PNPadmin@cwcc.org.kh PNPmanager@cwcc.org.kh

### ការិយាល័យខេត្តបន្ទាយមានជ័យ

- អាសយដ្ឋាន៖ ភូមិសាមគ្គីមានជ័យ សង្កាត់ប៉ោយប៉ែត ក្រុងប៉ោយប៉ែត
- ទូរស័ព្ទ ៖ (៨៥៥-៥៤) ៩៦៧ ១៩៤
- អ៊ីម៉ែល៖ BMCadmin@cwcc.org.kh BMCmanager@cwcc.org.kh

### ការិយាល័យខេត្តសៀមរាប

- អាសយដ្ឋាន៖ ភូមិស្វាយដង្គុំ សង្កាត់ស្វាយដង្គុំ ក្រុងសៀមរាប ខេត្តសៀមរាប
- ទូរស័ព្ទ៖ (៨៥៥-៦៣) ៩៦៣២៧៦
- អ៊ីម៉ែល៖ SRPadmin@cwcc.org.kh SRPmanager@cwcc.org.kh

### ការិយាល័យខេត្តកំពង់ធំ

- អាសយដ្ឋាន៖ ផ្លូវលេខ ៨ ភូមិដំរីជាន់ខ្លា សង្កាត់ដំរីជាន់ខ្លា ក្រុងស្ទឹងសែន ខេត្តកំពង់ធំ
- ទូរស័ព្ទ៖ (៨៥៥-៦២) ២១០៥១៥
- អ៊ីម៉ែល៖ KPTadmin@cwcc.org.kh KPTmanager@cwcc.org.kh

# សូមថ្លែងអំណរគុណចំពោះម្ចាស់ជំនួយដូចខាងក្រោម